## សុវត្ថិភាពនៃព័ត៌មានសុខភាពរបស់អ្នក

យើងធ្វើតាមស្តង់ដាររដ្ឋាភិបាលតឹងរឹងទាក់ទងនឹងការរក្សាទុកព័ត៌មានសុខភាពរបស់អ្នកឱ្យមានសុវត្ថិភាពគ្រប់ទម្រង់ទាំងអស់។ យើងពង្រឹងនិងធ្វើសវនកម្មប្រព័ន្ធរបស់យើងជាទៀងទាត់ ដើម្បីការពារព័ត៌មានរបស់អ្នកពីការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ឬការប្រើប្រាស់ខុស។

សេវាកម្មសុខភាពសាធារណៈនៃរដ្ឋញូវសៅវែល កាន់កាប់ព័ត៌មានសុខភាពជាឯកសារក្រដាស លើប្រព័ន្ធកំណត់ត្រាវេជ្ជសាស្ត្រអេឡិចត្រូនិក និង HealtheNet រដ្ឋញូវសៅវែល។

HealtheNet គឺជាកំណត់ត្រាអេឡិចត្រូនិកទូទាំងរដ្ឋដែលមានសុវត្ថិភាព ដែលត្រូវបានប្រើប្រាស់ដោយសេវាកម្មសុខភាពសាធារណៈនៃរដ្ឋញូវសៅវែល។ HealtheNet មានសេចក្ដីសង្ខេបនៃព័ត៌មានសុខភាពរបស់អ្នក ឧទាហរណ៍ សេចក្តីសង្ខេបនៃការចាកចេញពីមន្ទីរពេទ្យរបស់អ្នក រោគសាស្ត្រ និងលទ្ធផលនៃការធ្វើរោគវិនិច្ឆ័យ ហើយនិងព័ត៌មានអំពីថ្នាំពេទ្យ។

ប្រសិនបើអ្នកអញ្ជើញទៅកាន់សេវាសុខភាពសាធារណៈនៅគ្រប់ទីកន្លែងក្នុងរដ្ឋញូវសៅវែល ក្នុងករណីភាគច្រើន ព័ត៌មានសង្ខេបនេះនឹងមានផ្តល់សម្រាប់បុគ្គលិកគ្លីនិកព្យាបាលរបស់អ្នកតាមរយៈ HealtheNet។

## My Health Record (កំណត់ត្រាសុខភាពរបស់ខ្ញុំ)

My Health Record គឺជាប្រព័ន្ធកំណត់ត្រាសុខភាពឌីជីថលជាតិរបស់អូស្ត្រាលី។ ប្រជាជនអូស្ត្រាលីទាំងអស់មាន My Health Record លើកលែងតែអ្នកជ្រើសរើសមិនឱ្យមាន។

ប្រសិនបើអ្នកបានអញ្ជើញទៅសេវាកម្មសុខភាពសាធារណៈនៃរដ្ឋញូវសៅវែល សេចក្តីសង្ខេបនៃព័ត៌មានសុខភាពរបស់អ្នកនឹងត្រូវបានផ្ញើទៅ My Health Record របស់អ្នក។ បុគ្គលិកសេវាកម្មសុខភាពសាធារណៈនៃរដ្ឋញូវសៅវែល ក៏អាចពិនិត្យ និងផ្ញើព័ត៌មានទៅក្នុង My Health Record របស់អ្នកដែរ។

ប្រសិនបើអ្នកមាន My Health Record ប៉ុន្តែមិនប្រាថ្នាចង់ឱ្យព័ត៌មានរបស់អ្នកពីការណាត់ជួបវេជ្ជបណ្ឌិត ឬការទៅមន្ទីរពេទ្យណាមួយដើម្បីដាក់បញ្ចូលក្នុង My Health Record របស់អ្នក អ្នកត្រូវតែជូនដំណឹងដល់អ្នកផ្តល់សេវាកម្មសុខភាព នៅពេលចាប់ផ្តើមការទៅជួបរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែមអំពី My Health Record សូមទូរស័ព្ទលេខ 1800 723 471 ឬចូលទៅកាន់វ៉ិបសៃថ៍ www.myhealthrecord.gov.au

NSW GOVERNMENT | Health

## ទាក់ទងមកពួកយើង

ប្រសិនបើអ្នកមានសំណួរ ឬការតវ៉ាអំពីភាពឯកជននៃព័ត៌មានសុខភាពរបស់អ្នក សូមទាក់ទង  Privacy Contact Officer (មន្ត្រីទំនាក់ទំនងភាពឯកជន) នៅ NSW Health ដែលកាន់កាប់ព័ត៌មានសុខភាពរបស់អ្នក។

សម្រាប់ព័ត៌មានលម្អិតអំពី Privacy Contact Officer សូមចូលទៅកាន់វ៉ិបសៃថ៍ www.health.nsw.gov.au/patients/privacy/Pages/privacy-contact.aspx

## សេវាកម្មបកប្រែភាសាសរសេរ និងនិយាយ

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការទាក់ទងមកសេវាកម្មខាងលើ ឬតម្រូវការបកប្រែ សូមទូរស័ព្ទមកសេវាកម្មបកប្រែភាសាសរសេរ និងនិយាយ (TIS) លេខ 13 14 50។

សម្រាប់ខិត្តប័ណ្ណព័ត៌មានស្តីពីសិទ្ធិឯកជនជាភាសាផ្សេងទៀត សូមចូលទៅកាន់វ៉ិបសៃថ៍ Multicultural Health Communication Service នៅត្រង់៖ www.mhcs.health.nsw.gov.au

Khmer

# Privacy Leaflet for Patients

**How we protect your health information**

# ខិត្តប័ណ្ណស្តីពីសិទ្ធិឯកជនសម្រាប់អ្នកជំងឺ

## របៀបដែលយើងការពារព័ត៌មានសុខភាពរបស់អ្នក

NSW GOVERNMENT | Health

## ការប្រមូលព័ត៌មានសុខភាពរបស់អ្នក

ដើម្បីផ្តល់ជូនអ្នកនូវការព្យាបាលសមស្រប យើងអាចប្រមូលព័ត៌មានសុខភាពមួយចំនួនអំពីអ្នក។ នេះអាចរួមមានព័ត៌មានអំពីសុខភាពរបស់អ្នក រោគសាស្ត្ររបស់អ្នក និងលទ្ធផលនៃការធ្វើរោគវិនិច្ឆ័យ កាំរស្មីអ៊ិច និងរូបភាពផ្សេងៗទៀត ហើយនិងព័ត៌មានអំពីថ្នាំពេទ្យរបស់អ្នក។

យើងប្រមូលព័ត៌មានសុខភាពដោយផ្ទាល់ពីអ្នក ពេលណាដែលអាចធ្វើទៅបាន។ ប្រសិនបើមិនអាចធ្វើទៅបានទេ ឬក្នុងភាពអាសន្ន យើងអាចយោងទៅកំណត់ត្រាសុខភាពរបស់អ្នកពីមុន ពីអ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្សេងទៀត និង My Health Record (កំណត់ត្រាសុខភាពរបស់ខ្ញុំ)។

យើងក៏ប្រហែលជាចាំបាច់ត្រូវប្រមូលព័ត៌មានពីសមាជិកគ្រួសារម្នាក់ មិត្តភក្តិ អ្នកថែទាំ ឬមនុស្សផ្សេងទៀតដែរ ដូចជាអ្នកបកប្រែភាសា ដែលពួកគេអាចជួយយើងក្នុងការផ្តល់ការថែទាំសុខភាពសមស្របដល់អ្នក។

## ការប្រើប្រាស់ ឬការបញ្ចេញព័ត៌មានសុខភាពរបស់អ្នក

ព័ត៌មានសុខភាពរបស់អ្នក អាចត្រូវបានប្រើប្រាស់ដោយសេវាកម្មសុខភាពសាធារណៈនៃរដ្ឋញូវសៅវែល ឬបញ្ចេញទៅខាងក្រៅសេវាកម្មសុខភាពដើម្បីផ្តល់ជូនការថែទាំ និងការព្យាបាលសមស្របដែលផ្តល់ជូនអ្នក។

ជាឧទាហរណ៍ ព័ត៌មានរបស់អ្នកអាចត្រូវបានប្រើប្រាស់ ឬបញ្ចេញដូចខាងក្រោមនេះ៖

- ទៅសេវាកម្មសុខភាព មន្ទីរពេទ្យ ឬអ្នកឯកទេសខាងវេជ្ជសាស្ត្រដទៃទៀតដែលពាក់ព័ន្ធនឹងការថែទាំសុខភាពរបស់អ្នក។
- ទៅវេជ្ជបណ្ឌិតព្យាបាលរោគទូទៅដែលបានតែងតាំងរបស់អ្នក រួមទាំងព័ត៌មានដែលបានផ្តល់ ជាមួយឯកសារបញ្ជូនស្តីពីការចាកចេញពីមន្ទីរពេទ្យរបស់អ្នក។
- ទៅសេវាកម្មរថយន្តសង្គ្រោះបន្ទាន់នៃរដ្ឋញូវសៅវែល។
- ទៅ My Health Record។
- ដើម្បីទាក់ទងមកអ្នកនៅផ្ទះ ទាក់ទិននឹងការណាត់ជួបបន្ត។
- ទៅអ្នកថែទាំរបស់អ្នក ដើម្បីជួយជាមួយការថែទាំរបស់អ្នក។
- ដើម្បីទាក់ទងមកអ្នកសម្រាប់ព័ត៌មានផ្តល់មកវិញ អំពីសេវាកម្មដែលអ្នកបានទទួល។
- ទៅបុគ្គលិកថែទាំផ្នែកគ្រូគង្វាល រួមទាំងបព្វជិតមន្ទីរពេទ្យដែលផ្តល់ការថែទាំខាងវិញ្ញាណ និងខាងគ្រូគង្វាល។
- ទៅសិស្ស និងបុគ្គលិកដទៃទៀត សម្រាប់គោលបំណងបណ្តុះបណ្តាល។
- ទៅសេវាកម្មសុខភាពផ្សេងទៀត និងភាគីទីបីដែលមានការអនុញ្ញាត ដើម្បីជួយការពារពីការគំរាមកំហែងធ្ងន់ធ្ងរ និងជិតមានគ្រោះថ្នាក់ដល់អាយុជីវិត សុខភាព ឬសុខុមាលភាពរបស់នរណាម្នាក់ ដូចជាក្នុងករណីបន្ទាន់។
- សម្រាប់គោលបំណងទាក់ទងនឹងការបរិច្ចាគសរីរាង្គ ឬជាលិកា។ នេះអាចរាប់បញ្ចូលព័ត៌មានទំនាក់ទំនងលម្អិតរបស់ញាតិសន្តានបន្ទាប់។
- សម្រាប់សកម្មភាពប្រតិបត្តិការ និងការគ្រប់គ្រង រួមមានការផ្តល់មូលនិធិ ផែនការ សុវត្ថិភាព និងការកែលម្អគុណភាព។
- ដើម្បីស៊ើបអង្កេតបណ្តឹង ឬឧប្បត្តិហេតុ។
- ដើម្បីគ្រប់គ្រងបណ្តឹងតាមផ្លូវច្បាប់ ឬការទាមទារសំណងដោយអ្នកជំងឺជំទាស់នឹងសេវាកម្មសុខភាព។

**ប្រសិនបើអ្នកមិនចង់ឱ្យយើងប្រមូល ប្រើប្រាស់ ឬបង្ហាញព័ត៌មានជាក់លាក់អំពីអ្នកទេ អ្នកចាំបាច់ត្រូវប្រាប់យើង ហើយយើងនឹងពិភាក្សាជាមួយអ្នកអំពីផលវិបាកណាមួយដែលអាចមាន ចំពោះការថែទាំសុខភាពរបស់អ្នក។**

ច្បាប់ក៏អនុញ្ញាត ឬតម្រូវឱ្យបង្ហាញព័ត៌មានសុខភាពរបស់អ្នកដល់ភាគីទីបីផ្សេងទៀតដែរ ឧទាហរណ៍៖

- ទៅទីភ្នាក់ងាររដ្ឋាភិបាលរបស់រដ្ឋ និងសហព័ន្ធ សម្រាប់គោលបំណងរាយការណ៍តាមច្បាប់ ដូចជាដើម្បីរាយការណ៍ពីជំងឺឆ្លងជំងឺមហារីក និងជំងឺដែលតម្រូវឱ្យរាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ពីការកើត និងមរណភាព និងដើម្បីផ្តល់ព័ត៌មានលម្អិតអំពីមេឌីឃែរ។
- ទៅអ្នកស្រាវជ្រាវសម្រាប់គម្រោងស្រាវជ្រាវចំណាប់អារម្មណ៍សាធារណៈ ដែលត្រូវបានអនុម័តដោយ Human Research Ethics Committee (គណៈកម្មការសីលធម៌ខាងការស្រាវជ្រាវមនុស្ស)។
- ទៅសេវាកម្មសុខភាព ឬភ្នាក់ងារអនុវត្តច្បាប់ផ្សេងទៀតដូចជាប៉ូលីស ប្រសិនបើអ្នកផ្តល់ឱ្យយើងនូវព័ត៌មានទាក់ទងនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរ រួមមានការរំលោភបំពានធ្ងន់ធ្ងរ អំពើហឹង្សាក្នុងគ្រួសារ ឬការរំលោភបំពានលើកុមារ។
- ទៅទីភ្នាក់ងារផ្សេងទៀតដែលព័ត៌មានទាក់ទងនឹងសុវត្ថិភាពសុខុមាលភាព ឬសុខុមាលភាពរបស់កុមារ ឬមនុស្សវ័យក្មេង។
- ដើម្បីអនុវត្តតាមដីកាកោះសាក្សី ឬដីកាស្វែងរក ប្រសិនបើព័ត៌មានសុខភាពរបស់អ្នកត្រូវបានទាមទារជាភស្តុតាងនៅក្នុងតុលាការ។

## គ្រោងការណ៍ធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIS)

ប្រសិនបើអ្នក ឬនរណាម្នាក់ក្នុងនាមអ្នកផ្តល់មកយើងនូវច្បាប់ថតចម្លងនៃផែនការ NDIS របស់អ្នក ឬឯកសារ NDIS ផ្សេងទៀត យើងអាចប្រើប្រាស់ ឬផ្សព្វផ្សាយព័ត៌មាននេះក្នុងគោលបំណងទាក់ទងនឹងការថែទាំសុខភាព និងសេវាកម្មសង្គមរបស់អ្នក។ នេះអាចរាប់បញ្ចូលទាំងការចែករំលែកព័ត៌មានជាមួយទីភ្នាក់ងាររដ្ឋាភិបាលផ្នែកឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយដល់សេវាកម្មសុខភាព និងសេវាកម្មមិនមែនសុខភាពដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នក។

## ការចូលប្រើប្រាស់ព័ត៌មានរបស់អ្នក

អ្នកមានសិទ្ធិស្នើសុំសិទ្ធិចូលប្រើប្រាស់ព័ត៌មានសុខភាពរបស់អ្នកដែលកាន់កាប់ដោយពួកយើង។ ជាធម្មតា អ្នកនឹងត្រូវបានស្នើសុំដើម្បីចូលប្រើប្រាស់ជាលាយលក្ខណ៍អក្សរ និងផ្តល់អត្តសញ្ញាណប័ណ្ណ។ អ្នកអាចត្រូវគេគិតថ្លៃ ប្រសិនបើអ្នកស្នើសុំច្បាប់ចម្លងនៃកំណត់ត្រាសុខភាពរបស់អ្នក។ យើងឆ្លើយតបទៅនឹងការស្នើសុំព័ត៌មានឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ហើយក្នុងករណីភាគច្រើនដែលមិនលើសពី២៨ថ្ងៃទេ។

ការចូលប្រើប្រាស់ព័ត៌មានរបស់អ្នក អាចត្រូវបានគេបដិសេធក្នុងកាលៈទេសៈពិសេស ដូចជាពេលណាការផ្តល់សិទ្ធិចូលប្រើប្រាស់ដែលអាចដាក់អ្នក ឬមនុស្សម្នាក់ទៀតមានគ្រោះថ្នាក់ដល់ផ្លូវចិត្ត ឬរាងកាយ។

ប្រសិនបើអ្នកជឿថា ដែលយើងរក្សាទុកអំពីអ្នកមិនត្រឹមត្រូវ ឬមានកំហុសណាមួយ សូមប្រាប់យើងឱ្យបានដឹង ហើយយើងនឹងកែតម្រូវវា ឬបន្ថែមកំណត់ចំណាំលើកំណត់ត្រាសុខភាពរបស់អ្នក។

សំណូមពរដើម្បីចូលប្រើប្រាស់កំណត់ត្រាសុខភាពរបស់អ្នក គួរតែបញ្ជូនទៅ Medical Records Department ឬអ្នកគ្រប់គ្រងទីកន្លែងសេវាកម្មសុខភាពដែលអ្នកបានអញ្ជើញទៅ។